ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
# ស្តីពី
# ករណីព្យាបាលជាសះស្បើយ ០១នាក់
# និងមិនមានករណីវិជ្ជមានកូវីដ១៩ ថ្មី នៅថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២០

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ៖

**១. ស្ថានភាពជំងឺកូវីដ ១៩ នៅទូទាំងប្រទេស ៖**

ត្រឹមម៉ោង០៧:០០ព្រឹក ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២០ ស្ថានភាពជំងឺកូវីដ១៩ នៅកម្ពុជា មាន៖

- **អ្នកព្យាបាលជាសះស្បើយ** សរុបចំនួនកើនដល់ **៥០នាក់** (ស្មើនឹង ៤៣,៨៥% ធៀបនឹងចំនួនអ្នកមានវីរុសកូវីដ១៩ទាំងអស់) ដែលមានបុរសជនជាតិចិន ០១នាក់ ស្ត្រីជនជាតិអង់គ្លេស ០២នាក់ បុរសជនជាតិអង់គ្លេស ០១នាក់ បុរសជនជាតិបែលហ្ស៊ិក ០១នាក់ បុរសជនជាតិបារាំង ០៤នាក់ (ក្នុងនេះមានទារកអាយុ ០៤ខែ) ស្ត្រីជនជាតិបារាំង ០៩នាក់ បុរសជនជាតិម៉ាឡេស៊ី ០៤នាក់ បុរសជនជាតិខ្មែរ ២៣នាក់ និងស្ត្រីជនជាតិខ្មែរ ០១នាក់ (គិតចាប់ពីខែមករាដល់បច្ចុប្បន្ននេះ)។
- **អ្នកដែលកំពុងសម្រាកព្យាបាល** បានថយចុះមកនៅសរុបចំនួន **៦៤នាក់** (ស្ត្រី ២០នាក់ និងបុរស ៤៤នាក់) នៅតាមមន្ទីរពេទ្យថ្នាក់ជាតិ និងថ្នាក់ខេត្ត
- **អ្នកមានវីរុសកូវីដ១៩ ដែលបានរកឃើញទាំងអស់** (រាប់ទាំងអ្នកដែលបានព្យាបាលជាសះស្បើយ និងអ្នកដែលកំពុងព្យាបាល) នៅទូទាំងប្រទេសសរុបចំនួន **១១៤នាក់** (ស្ត្រី ៣២នាក់ និងបុរស ៨២នាក់) ដែលចំនួននេះ មិនមានកើនទេ។

**២. ករណីជាសះស្បើយ៖** មាន ០១នាក់ ជាបុរសអាយុ ៦២ឆ្នាំ ជនជាតិម៉ាឡេស៊ី ជាក្រុមមកធ្វើការងារសាសនា ស្នាក់នៅស្រុកកងមាស ខេត្តកំពង់ចាម បានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ១៩ ចំនួន០២លើក ត្រូវបានអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យខេត្តកំពង់ចាម។

**៣. មិនមានករណី វិជ្ជមានវីរុសកូវីដ ១៩ ថ្មី** នៅថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២០។



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

ក្រុមការងាររបស់ក្រសួងសុខាភិបាល កំពុងតែធ្វើកិច្ចការស្រាវជ្រាវករណីថ្មីជាបន្តទៀត ហើយនឹងបន្តជម្រាបជូនដល់បងប្អូនសាធារណជន ប្រសិនបើមានរកឃើញករណីវិជ្ជមានវីរុសកូវីដ១៩ ថ្មីណាផ្សេងទៀត។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃអាទិត្យ ១៣កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
ភ្នំពេញ ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២០

វេជ្ជបណ្ឌិត **ឱ វណ្ណឌីន**
រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យ
ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា